# បញ្ចសិខគីតគាថា

(កាថាចម្រៀងស្នេហ៍របស់បញ្ចសិខគន្ធព្វទេវបុត្រ)



វន្ទេ តេ បិតរំ ភទ្ទេ, តិម្ពរុំ សូរិយវច្ឆសេ;
យេន ជាតាសិ កល្យាណី, អានន្ទជននី មម។

ម្នាលនាងសុរិយវច្ឆសាដ៏ចម្រើន បងសូមថ្វាយបង្គំនូវទេវរាជព្រះនាមតិម្ពរុ ជាបិតារបស់នាង ដោយហេតុដែលនាងកើតមកហើយ មានលម្អជាទីញ៉ាំងសេចក្តីត្រេកអរ ឲ្យកើតដល់បង ។

វាតោវ សេទតំ កន្តោ, បានីយំវ បិបាសតោ;
អង្គីរសិ បិយាមេសិ, ធម្មោ អរហតាមិវ។

ដូចខ្យល់ជាទីត្រេកអររបស់បុគ្គលអ្នកមានញើស ពុំនោះសោត ដូចទឹកសម្រាប់ផឹកជាទីត្រេកអររបស់បុគ្គលអ្នកស្រេកទឹក នាងមានពន្លឺរស្មីនៃអវយវៈ ជាទីស្រឡាញ់ពេញចិត្តនៃបង ដូចនវលោកុត្តរធម៌ ជាទីស្រឡាញ់របស់ពួកព្រះអរហន្តដូច្នោះ ។

អាតុរស្សេវ ភេសជ្ជំ, ភោជនំវ ជិឃច្ឆតោ;
បរិនិព្ពាបយ មំ ភទ្ទេ, ជលន្តមិវ វារិនា។

ម្នាលនាងដ៏ចម្រើន ចូរនាងជួយលត់ (សេចក្តីក្រហល់ក្រហាយរបស់បង) ចេញ ដូចគេដាក់ថ្នាំដល់អ្នកជំងឺ ពុំនោះដូចគេឲ្យភោជនដល់អ្នកកំពុងឃ្លាន ពុំនោះសោត ដូចគេលត់ភ្លើងកំពុងឆេះដោយទឹក ។

សីតោទកំ បោក្ខរណឹ, យុត្តំ កិញ្ជក្ខរេណុនា;
នាគោ ឃម្មាភិតត្តោវ, ឱគាហេ តេ ថនូទរំ។

សូមឲ្យបងបានអែបនែបត្រង់ចន្លោះស្តន និងឧទររបស់នាង ដូចជាដំរីមានសេចក្តីក្រហល់ក្រហាយក្នុងរដូវប្រាំង បានចុះកាន់ស្រះឈូកមានទឹកដ៏ត្រជាក់ ប្រកបដោយលម្អងនៃកេសរផ្កាឈូកដូច្នោះឯង ។

អច្ចង្កុសោវ នាគោវ, ជិតំ មេ តុត្តតោមរំ;
ការណំ នប្បជានាមិ, សម្មត្តោ លក្ខណូរុយា។

បងផោងផប់ព្រោះភ្លៅរបស់នាង ដែលបរិបូណ៌ដោយលក្ខណៈ ក៏លែងស្គាល់ហេតុ (ដែលនាំឲ្យប្រាសចាកភគៈ) ដូចជាដំរី (ចុះប្រេង) ហួសវិស័យកង្វេរ គិតថា អញឈ្នះផ្ទៃ កង្វេរនិងលំពែង ។

តយិ គេធិតចិត្តោស្មិ, ចិត្តំ វិបរិណាមិតំ;
បដិគន្តុំ ន សក្កោមិ, វង្កឃស្តោវ អម្ពុជោ។

បងមានចិត្តស្អុងចុះហើយក្នុងនាង បងមិនអាចនឹងទាញចិត្តដែលងប់ស៊ប់ហើយ ឲ្យត្រឡប់វិញបានឡើយ ដូចជាត្រីលេបសន្ទូច ។

វាមូរុ សជ មំ ភទ្ទេ, សជ មំ មន្ទលោចនេ;
បលិស្សជ មំ កល្យាណិ, ឯតំ មេ អភិបត្ថិតំ។

ម្នាលនាងមានភ្លៅដូចបណ្តូលចេកដ៏ចម្រើន ចូរនាងឱបបង ម្នាលនាងមានភ្នែកស្រទន់ ចូរនាងមកកៀកបង ម្នាលនាងមានរូបឆោមដ៏ល្អ ចូរនាងមកឱបរឹតបង ការឱបរឹតនេះ បងត្រូវការណាស់ ។

អប្បកោ វត មេ សន្តោ, កាមោ វេល្លិតកេសិយា;
អនេកភាវោ សមុប្បាទិ, អរហន្តេវ ទក្ខិណា។

កាមរបស់បងមានតិចដែរទេ តែព្រោះនាងមានសក់ត្រសាយងឡើង សេចក្តីប្រាថ្នានៃបង ក៏កើតមានជាអនេក ដូចទក្ខិណាទានដែលគេថ្វាយចំពោះព្រះអរហន្ត ។

យំ មេ អត្ថិ កតំ បុញ្ញំ, អរហន្តេសុ តាទិសុ;
តំ មេ សព្ពង្គកល្យាណិ, តយា សទ្ធិំ វិបច្ចតំ។

ម្នាលនាងមានលម្អសព្វសព៌ាង្គ បុណ្យណាដែលបងបានធ្វើហើយ ចំពោះព្រះអរហន្តទាំងឡាយ ជាអ្នកនឹងធឹង បុណ្យរបស់បងនោះ សូមជួយបងឲ្យបានកប់ប្រសព្វនឹងនាង ។

យំ មេ អត្ថិ កតំ បុញ្ញំ, អស្មិំ បថវិមណ្ឌលេ;
តំ មេ សព្ពង្គកល្យាណិ, តយា សទ្ធិំ វិបច្ចតំ។

ម្នាលនាងមានលម្អអស់អង្គ បុណ្យណាដែលបងបានធ្វើហើយ ក្នុងមណ្ឌលនៃប្រឹថពីនេះ បុណ្យរបស់បងនោះ សូមជួយបងឲ្យបានកប់ប្រសព្វនឹងនាង ។

សក្យបុត្តោវ ឈានេន, ឯកោទិ និបកោ សតោ;
អមតំ មុនិ ជិគីសានោ, តមហំ សូរិយវច្ចសេ។

ព្រះមុនីជាសក្យបុត្រ ទ្រង់ប្រកបដោយឈាន គង់នៅតែមួយព្រះអង្គឯង មានព្រះប្រាជ្ញាស្មារតី ព្រះអង្គខំស្វែងរកព្រះនិព្វាន យ៉ាងណា ម្នាលនាងសុរិយវច្ចសា បងក៏ខំស្វែងរកនាង យ៉ាងនោះដែរ ។

យថាបិ មុនិ នន្ទេយ្យ, បត្វា សម្ពោធិមុត្តមំ;
ឯវំ នន្ទេយ្យំ កល្យាណិ, មិស្សីភាវំ គតោ តយា។

*មួយទៀត សម្ដេចព្រះមុនី ព្រះអង្គបានសម្រេចនូវសម្ពោធិញ្ញាណដ៏ឧត្ដមហើយ ទ្រង់រីករាយព្រះហឫទ័យ យ៉ាងណាមិញ ម្នាលនាងកល្យាណី ខ្ញុំបងបើបានមូលមិត្តនឹងនាងហើយ ក៏នឹងរីករាយក្នុងចិត្ត យ៉ាងនោះដែរ ។*

សក្កោ ចេ មេ វរំ ទជ្ជា, តាវតឹសានមិស្សរោ;
តាហំ ភទ្ទេ វរេយ្យាហេ, ឯវំ កាមោ ទឡ្ហោ មម។

*ម្នាលនាងដ៏ចម្រើន បើសក្កទេវរាជជាធំជាងពួកទេវតាក្នុងជាន់តាវត្តិង្ស ទ្រង់ប្រទានពរដល់បង បងគប្បីប្រាថ្នានាង សេចក្ដីប្រាថ្នាដែលមាំមួន (ក្នុងចិត្ត) របស់បងយ៉ាងនេះ ។*

សាលំវ ន ចិរំ ផុល្លំ, បិតរំ តេ សុមេធសេ;
វន្ទមានោ នមស្សាមិ, យស្សា សេតាទិសី បជា។

*ម្នាលនាងទេវធីតាមានប្រាជ្ញាឈ្លាសវៃ នាងមានរូបប្រាកដដូច្នេះ ជាធីតារបស់អ្នកណា បងសូមថ្វាយបង្គំចំពោះអ្នកនោះ ជាបិតារបស់នាង ដូចឈើដែលទើបនឹងមានផ្កា ។*

*(សុត្តន្តបិដក ទីឃនិកាយ មហាវគ្គ សក្កបញ្ហសូត្រ បិដកលេខ ១៧ ទំព័រ ១៩៥)*

*ដោយសជវថ*